00250109

E5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ ចៅក្រម និល ណុន ប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម យ៉ា សុខន
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម ធូ មណី

កាលបរិច្ឆេទ ១១ ខែ ធ្នូ ឆ្នាំ ២០០៨
ចំណាត់ថ្នាក់ឯកសារ សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / DEC / 2008
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

---

**សេចក្តីជូនដំណឹងពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឲ្យភាគីដាក់ឯកសារបន្ថែម**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ បញ្ជាក់ (Certified Date/Date de certification): 11 / DEC / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

TRIAL CHAMBER / CHAMBRE DE PREMIÈRE INSTANCE — E.C.C.C. / E.T.C.

យើងចៅក្រម **និល ណុន** ជាប្រធានអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)

**ក្នុងនាម** អង្គជំនុំជម្រះសាលាដំបូង

**អនុលោមតាម** បទប្បញ្ញត្តិនៃវិធាន៧៩ និង៨០ នៃវិធានផ្ទៃក្នុង (“វិធាន”)

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង តាមសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ដែលអង្គបុរេជំនុំជម្រះបានសម្រេចនិងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្ដីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ (“សេចក្ដីសម្រេច”)

**បានឃើញ** សាលដីកាខាងលើដែលបានចោទប្រកាន់លើឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ភេទប្រុស សញ្ជាតិខ្មែរ កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ដោយបញ្ជូនឈ្មោះនេះមកជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីបទ ៖

តាមរយៈការប្រព្រឹត្តរបស់គាត់ និងការមិនបានទប់ស្កាត់មិនឲ្យមានការប្រព្រឹត្តនៅក្នុងភ្នំពេញ និងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ មករា ឆ្នាំ ១៩៧៩ ក្នុងឋានៈជាលេខារង និងលេខាមន្ទីរ ស ២១ ដែលបានរៀបចំផែនការ ញុះញង់ បញ្ជា និងបានប្រព្រឹត្ត ឬជួយនិងការជម្រុញ ឬជាអ្នកទទួលខុសត្រូវជាន់ខ្ពស់នូវបទល្មើសឧក្រិដ្ឋកម្មដូចខាងក្រោម ៖

១. **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឱ្យទៅជាទាសករ
- ការដាក់ក្នុងមន្ទីឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

- និងអំពើអមនុស្សធម៌ផ្សេងៗទៀត

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា២៩(ថ្មី) មាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**២. ការបំពានបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩**

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបាននូវការកាត់ទោសដោយយុត្តិធម៌និងឆាប់រហ័ស។
- ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦ មាត្រា២៩(ថ្មី) មាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**៣. ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦**

- បទមនុស្សឃាតគិតទុកជាមុន (មាត្រា ៥០១ និងមាត្រា ៥០៦)
- បទទារុណកម្ម (មាត្រា ៥០០)

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣(ថ្មី) មាត្រា២៩(ថ្មី) មាត្រា៣៩(ថ្មី)នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**ដោយយល់ឃើញថា** តាមបទប្បញ្ញត្តិនៃមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថាសវនាការប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយ

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE C C C E T C

មានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី ។

ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តទៅ នៃកិច្ចដំណើរការណ៍នីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ក្នុងសំណុំរឿងលេខ០០១/១៨-០៧-២០០៧/អវតក/អជសង ដែលមានជនជាប់ចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច ៖

## ហេតុដូច្នេះសម្រេច

១. **កំណត់កាលបរិច្ឆេទ** កិច្ចប្រជុំរៀបចំសវនាការ ("កិច្ចប្រជុំ") នៅថ្ងៃព្រហស្បតិ៍ ទី១៥ ខែ មករា ឆ្នាំ ២០០៩ និងថ្ងៃសុក្រ ទី១៦ ខែ មករា ឆ្នាំ ២០០៩ នៅសាលសវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

២. **អញ្ជើញចូលរួម** ក្នុងកិច្ចប្រជុំនេះមាន សហព្រះរាជអាជ្ញាឬអ្នកតំណាង ជនជាប់ចោទនិងមេធាវីការពារក្តីរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីតំណាងរបស់ខ្លួន ។

៣. **អញ្ជើញចូលរួម** ក្នុងកិច្ចប្រជុំនេះផងដែរ មានអ្នកតំណាងពីររូប ពីផ្នែកនិងអង្គភាពពាក់ព័ន្ធ ដូចខាងក្រោម ៖

- ផ្នែកគ្រប់គ្រងតុលាការ ("CMS")
- ផ្នែកគាំពារការការពារក្តី ("DSS")
- អង្គភាពមន្ទីរឃុំឃាំង តាមរយៈមន្ត្រីទទួលបន្ទុកទំនាក់ទំនងមន្ទីរឃុំឃាំង
- អង្គភាពជនរងគ្រោះ
- អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU")

យោងតាមវិធាន៧៩.៧ នៃវិធានផ្ទៃក្នុង កិច្ចប្រជុំនេះនឹងត្រូវធ្វើឡើងជាអសាធារណៈ។ ភាគីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងអ្នកចូលរួមដទៃទៀតក្នុងកិច្ចប្រជុំនេះមិនតម្រូវឲ្យស្លៀកពាក់រ៉ូបទេ។ ដំណើរការនៃកិច្ចប្រជុំនេះនឹងរៀបចំឲ្យមានធ្វើកំណត់ហេតុជាលាយលក្ខអក្សរ ប្រតិចារិក និងថតសោតទស្សន៍ផងដែរ។ ប្រតិចារិកដែលត្រូវផ្សព្វផ្សាយជាសាធារណៈ នឹងត្រូវធ្វើឡើងបន្ទាប់ពីបានធ្វើការកែសម្រួលតាមការចាំបាច់រួចរាល់ហើយ។

របៀបវារៈបឋមនៃកិច្ចប្រជុំនេះត្រូវបានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធនៃឯកសារនេះ។ ក្នុងករណីមិនអាចបញ្ចប់កិច្ចប្រជុំនេះទៅតាមពេលវេលាដែលបានកំណត់ កិច្ចប្រជុំនេះនឹងត្រូវបន្តនៅថ្ងៃបន្តបន្ទាប់តាមការចាំបាច់។

៤. **បង្គាប់** ឱ្យភាគីទាំងអស់ដាក់ឯកសារបន្ថែមដូចខាងក្រោម ទៅឱ្យក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ក្នុងពេលជាមួយគ្នានៃការដាក់បញ្ជីឈ្មោះសាក្សី ដូចដែលមានចែងក្នុងវិធាន៨០ នៃវិធានផ្ទៃក្នុង:

ក) ឯកសារត្រូវដាក់ជាមួយគ្នានឹងបញ្ជីឈ្មោះសាក្សីតាមវិធាន៨០ នៃវិធានផ្ទៃក្នុង:

១) សេចក្តីសង្ខេបនៃអង្គហេតុ ដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្មបញ្ជាក់។ អនុលោមតាមវិធានការការពារណាមួយដែលអាចត្រូវចេញ សេចក្តីសង្ខេបគួរមានលក្ខណៈរៀបរាប់គ្រប់គ្រាន់ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតវាយតម្លៃខ្ពស់ និងយល់បាននូវលក្ខណៈនិងខ្លឹមសារនៃការធ្វើសក្ខីកម្ម ដែលបានស្នើសុំធ្វើនោះ ។

២) ចំណុចនានានៃការចោទប្រកាន់ ដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្មរួមទាំងកថាខណ្ឌ និងបទចោទជាក់លាក់ ។

៣) ការប៉ាន់ស្មានអំពីរយៈពេល ដែលតម្រូវឱ្យសាក្សីម្នាក់ៗធ្វើសក្ខីកម្ម ។

៤) ការបញ្ជាក់អំពីសាក្សី ដែលកំពុងស្ថិតក្រោមវិធានការការពារ ដោយយោងទៅលើសេចក្តីសម្រេចដែលពាក់ព័ន្ធក្នុងការផ្តល់វិធានការបែបនេះ និង

៥) ការបញ្ជាក់ពីភាសា ដែលសាក្សីនិយាយពេលធ្វើសក្ខីកម្ម

ខ) បញ្ជីវត្ថុតាង ដែលមានលក្ខណៈរូបី ដែលភាគីទាំងឡាយមានបំណងប្រគល់ឱ្យសម្រាប់រឿងក្តីនេះដោយមាន ពិពណ៌នាត្រួសៗ អំពីលក្ខណៈ និងខ្លឹមសារនៃវត្ថុតាងទាំងនោះ ។

គ) បញ្ជីឯកសារថ្មី ដែលភាគីទាំងឡាយមានបំណងប្រគល់ឱ្យសម្រាប់រឿងក្តីនេះដោយមាន ពិពណ៌នាត្រួសៗ អំពីលក្ខណៈ និងខ្លឹមសារនៃឯកសារទាំងនោះ ។

ឃ) ការបង្ហាញអំពីអង្គច្បាប់ ដែលភាគីទាំងឡាយមានបំណងលើកឡើងក្នុងសវនាការបឋមប្រសិនបើមាន ។

៥. **បង្គាប់** ឱ្យភាគីទាំងអស់ ដែលមានបំណងដាក់របៀបវារៈបន្ថែម ត្រូវជូនដំណឹងទៅ[illegible] អង្គជំនុំជម្រះសាលាដំបូង ជាលាយលក្ខអក្សរយ៉ាងយូរត្រឹមថ្ងៃច័ន្ទ ទី៥ ខែ មករា ឆ្នាំ ២០[illegible]។ [illegible] ភាគីទាំងអស់គួរបញ្ជាក់ថា តើខ្លួនមានបញ្ហាចោទជាក់លាក់ណាមួយទាក់ទងទៅនឹង[illegible]

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

របស់ផ្នែក និង/ឬអង្គភាពរបស់ អ.វ.ត.ក ដែរឬទេពាក់ព័ន្ធនិងដំណើរការនៃការជំនុំជម្រះ ដែលខ្លួនមានបំណងចង់លើកឡើងក្នុងកិច្ចប្រជុំនោះ។

៦. **បង្គាប់** ឲ្យភាគីដែលមានបំណងចង់ចូលរួមក្នុងកិច្ចប្រជុំនេះតាមរយៈទូរគមនាគមន៍និងវីដេអូ (ប្រសិនបើអាចធ្វើបាន) ត្រូវជូនដំណឹងទៅក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងជាលាយលក្ខអក្សរ យ៉ាងយូរត្រឹមថ្ងៃច័ន្ទ ទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨ ។

៧. **បង្គាប់ផងដែរថា** សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់គ្រប់ភាគីទាំងអស់ និងអង្គភាពជាប់ពាក់ព័ន្ធរបស់ អ.វ.ត.ក ដោយយោងតាមវិធាន៤៦ និងវិធាន៤៧ នៃវិធានផ្ទៃក្នុង និងត្រូវផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ភ្នំពេញ ថ្ងៃ ព្រហស្បតិ៍ ទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C • C E T C

និល ‑ ណុន